# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

**រដ្ឋាករទឹកស្វយ័តសៀមរាប**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ.០៩៧/២៤.....រសស.សជណ

## សេចក្តីជូនដំណឹង (លើកទី២)
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់សម្ភារការដ្ឋាន និងសម្ភាររោងជាង

រដ្ឋាករទឹកស្វយ័តសៀមរាប សូមជូនដំណឹងដល់បណ្តា ក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តសៀមរាប នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់សម្ភារការដ្ឋាន និងសម្ភាររោងជាង។

រដ្ឋាករទឹកស្វយ័តសៀមរាប បានរៀបចំឯកសារសម្រាប់ ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃរដ្ឋាករទឹកស្វយ័តសៀមរាប ដែលមានអាសយដ្ឋានស្ថិតនៅទីតាំងខាងកើតស្ពានថ្មព្រះរាជដំណាក់ ជាប់ផ្លូវជាតិលេខ៦ ភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប **ចាប់ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤** រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ០៦៣ ៩៦៣ ០២៥)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ **វេលាម៉ោង១០ម៉៣០នាទីព្រឹក ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤**។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅរដ្ឋាករទឹកស្វយ័តសៀមរាប តាមអាសយដ្ឋានខាងលើ វេលាម៉ោង **១០ម៉៣០នាទីព្រឹក ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤**។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ.សុក្រ..១១កើត...ខែចេត្រ..ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
ធ្វើនៅសៀមរាប ថ្ងៃទី..១៩...ខែមេសា.ឆ្នាំ២០២៤
ជ.**ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**ង៉ែត មុនីរ័ត្ន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ